# នមស្សការ បទបវរ្យាវត្ត

**នមោ អរហតោ សម្មា សម្ពុទ្ធស្ស មហេសិនោ**

សូមថ្វាយបង្គំឆ្ពោះព្រះអរហន្ត សម្ពុទ្ធភគវន្តកាលស្វែងរកធម៌
គឺពោធិញ្ញាណប្រសើរបវរ បានត្រាស់ដឹងធម៌ដោយអរិយមគ្គ ។

**នមោ ឧត្តម ធម្មស្ស ស្វាក្ខាតស្សេវ តេនិធ**

សូមថ្វាយបង្គំព្រះធម៌ឧត្តម ដែលព្រះបរមសម្ពុទ្ធសំដែង
ដោយប្រពៃពិតប្រាកដជាក់ស្តែង ព្រះធម៌នោះឯងទុកក្នុងសាសនា ។

**នមោ មហាសង្ឃស្សាបិ វិសុទ្ធសីល ទិដ្ឋិនោ**

សូមថ្វាយបង្គំព្រះសង្ឃប្រសើរ ដែលលោកបានធ្វើទិដ្ឋិនិងសីល
ឱ្យបានបរិសុទ្ធផុតចាកមន្ទិល គឺទិដ្ឋិសីលលោកស្អាតអស់ហើយ ។

**នមោ ឱមាត្យារទ្ធស្ស រតនត្តយស្ស សាធុកំ**

សូមថ្វាយបង្គំប្រជុំត្រ័យរ័ត្ន ប្រារព្ធដោយបទមានបីប្រការ
ព្រះពុទ្ធព្រះធម៌ព្រះសង្ឃឈ្នះមារ ប្រសើរអស្ចារ្យថ្លឹងថ្លែងពុំបាន ។

**នមោ ឱមកាតីតស្ស តស្ស វត្ថុត្តយស្សបិ**

សូមថ្វាយបង្គំភ្ញុំវត្ថុបី ពិសេសពិសីប្រសើរថ្កើងថ្កាន
ព្រះពុទ្ធព្រះធម៌ព្រះសង្ឃសព្វប្រាន ថយឬកល្យាណដោយគុណគួរគាប់ ។

**នមោ ការប្បភាវេន វិគច្ឆន្តុ ឧបទ្ទវា**

សូមថ្វាយបង្គំត្រ័យរ័ត្នសោភា ឧបទ្រពនានាចូរវិនាសបាត់
ដោយអានុភាពបុណ្យជួយកំចាត់ ធ្វើក្តីវិបត្តិឱ្យស្ងាត់ស្ងួនទៅ ។

**នមោ ការានុភាវេន សុវត្ថិ ហោតុ សព្វទា**

សូមថ្វាយបង្គំត្រ័យរ័ត្នទាំងបី សូមសុខសួស្តីកើតសព្វវេលា
ដោយអានុភាពធ្វើការវន្ទា គោរពបូជាឆ្ពោះព្រះត្រ័យរ័ត្ន ។

**នមោ ការស្ស តេជេន វិធិម្ហិ ហោមិ តេជវា**

សូមថ្វាយបង្គំត្រ័យរ័ត្នសោភា តេជះចេស្តាចូរមានដល់ខ្ញុំ
ក្នុងពិធីធ្វើកិច្ចថ្វាយបង្គំ តេជះបុណ្យធំសូមកើតមានឡើង ។

ចម្លងពីច្បាប់ដើមរបស់លោកគ្រូអាចារ្យ វ៉ាន់ អ៊ុង ដោយខ្ញុំព្រះករុណា ខ្ញុំបាទ លី អឿន ព.ស.២៥៥៤

ពិនិត្យហើយនិងដាក់គេហទំព័រវត្តដោយខ្ញុំបាទ **អ៊ិន លី** ថ្ងៃទី១៩ ខែមីនា គ.ស.២០១២